ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបតំណាងប្រចាំកម្ពុជា នៃធនាគារពិភពលោក **(WB)**



នៅរសៀលថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ២០១៥ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលជួប លោក **Alassane Sow** តំណាងប្រចាំកម្ពុជា នៃធនាគារពិភពលោក (WB) និងសហការី ដើម្បីពិភាក្សាការងារនៅទីស្តីការក្រសួង ។



លោក **Alassane Sow** តំណាងប្រចាំកម្ពុជា នៃធនាគារពិភពលោក (WB) បានជម្រាបជូនពីគោលបំណង នៃជំនួបពិភាក្សា គឺដើម្បីធ្វើសេចក្តីរាយការណ៍សង្ខេបពីវឌ្ឍនភាព នៃការអនុវត្តគម្រោងចំនួន២ ដែលជាជំនួយបច្ចេកទេស របស់ធនាគារពិភពលោក តាមរយៈកម្មវិធីទឹកស្អាត និងអនាម័យ (WSP) នៃធនាគារពិភពលោក (WB) ដែលគម្រោងទាំង

ពីរនោះ រួមមានទី១:គម្រោងបង្កើតប្រព័ន្ធព័ត៌មានគ្រប់គ្រងប្រតិបត្តិករទឹកស្អាតទូទាំងប្រទេស (Establish of a Monitoring for Water Sector )និងទី២: សេចក្តីព្រាងបញ្ញត្តិសេដ្ឋកិច្ច និងវិធីសាស្រ្តកំណត់ថ្លៃទឹក (Draft Economic Regulation & Tariff Methodology) ចំពោះកម្មវិធីអនុវត្តគម្រោងទី១:ក្រុមធនាគារពិភព លោក បានរាយការណ៍ថា: នៅខែមិថុនា ដល់ខែសីហា ឆ្នាំ២០១៤ គឺការចាប់ផ្តើមអនុវត្តគម្រោងដំណាក់កាលទី១–ខែមិថុនា ឆ្នាម២០១៤ ដល់ខែមិថុនា ឆ្នាំ២០១៥ ការរៀបចំរចនាសម្ព័ន្ធ និងតម្រូវការ នៃដំណើរការអាជីវកម្មទឹកស្អាត–ខែមេសា ដល់ខែសីហា ឆ្នាំ២០១៥ ការបង្កើតប្រព័ន្ធ និងដំណើរការសាកល្បង ចំពោះអង្គភាពគំរូ នៅខេត្តកំពង់ចាម និង ខេត្តកណ្តាល–សប្តាហ៍ ទី១ និងទី២ ខែកក្កដា ឆ្នាំ២០១៥ អនុវត្តការងារបណ្តុះបណ្តាលមន្រ្តីនាយកដ្ឋានទឹកស្អាត ប្រធាន និងមន្រ្តីទទួលបន្ទុកទឹកស្អាត នៅខេត្តកំពង់ចាម និងខេត្តកណ្តាល–ខែសីហា ដល់ខែធ្នូ ឆ្នាំ២០១៥ អនុវត្តការងារបណ្តុះបណ្តាលប្រធាន និងមន្រ្តីមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ទាំង២៥ ខេត្ត រាជធានី ស្តីពីការរៀបចំបញ្ចូលព័ត៌មាន និងការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធទូទាំងប្រទេស ។

ចំពោះការអនុវត្តគម្រោងទី២ ក្រុមធនាគារពិភពលោក បានបញ្ជាក់ថា:គម្រោងនេះបានចាប់ផ្តើមអនុវត្ត នៅខែតុលា ឆ្នាំ២០១៥ ។ ចាប់តាំងពីការចាប់ផ្តើមមកដល់បច្ចុប្បន្ន ការងារដែលជាលទ្ធផលគួរកត់សំគាល់នោះ គឺ: នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥ នាយកដ្ឋានទឹកស្អាត និងកម្មវិធី WSP បានរៀបចំសិក្ខាសាលាស្តីពីការអនុវត្តសាកល្បងវិធីសាស្រ្តកំណត់ថ្លៃទឹកសម្រាប់អង្គភាពរដ្ឋាករទឹក ខេត្តកំពង់ចាម ស្វាយរៀង និងក្រុមហ៊ុនទឹកស្អាតខេត្តក្រចេះ ។ អង្គប្រជុំនេះទទួលលទ្ធផល ដូចតទៅ គឺ: បានពិនិត្យ និងកែសម្រួលលើសូចនាករមួយចំនួនលើវិធីសាស្រ្តកំណត់ថ្លៃទឹក និងបានសាកល្បងបញ្ចូលទិន្នន័យរបស់អង្គភាពទាំង៣ខេត្ត ក្នុងរូបមន្តដែលបានបង្កើតរួចនេះ ។

ចំពោះកម្មវិធីដែលត្រូវអនុវត្តបន្តកម្មវិធី WSP និងរៀបចំដាក់មកក្រសួងនូវសេចក្តីព្រាងប្រកាសបឋមលើការត្រួតពិនិត្យ ឡើងវិញ និងការកំណត់ថ្លៃទឹកជាភាសាអង់គ្លេស និងខ្មែរ ។ នៅថ្ងៃទី ៣០ ខែមិថុនា ២០១៥ កម្មវិធី WSP និងរៀបចំដាក់មកក្រសួងនូវគំរូគណនាថ្លៃទឹកចុងក្រោយ ។ នៅថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ២០១៥ កម្មវិធី WSP និងរៀបចំគោលការណ៍បណ្តុះបណ្តាលពីរបៀបប្រើគំរូគណនា ដោយរួមទាំងឯកសារ និងគំរូ ដែលជាឧទាហរណ៍ជាក់ស្តែង និងរបាយការណ៍ចុងក្រោយ ស្តីពីការងារបញ្ញត្តកម្មកំណត់ថ្លៃទឹកសម្រាប់ប្រតិបត្តិវិស័យទឹកស្អាតនៅកម្ពុជា ។ ថ្ងៃទី២១ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥ កម្មវិធី WSP នឹងរៀបចំសិក្ខាសាលាស្តីពីការអនុវតយ្តសាកល្បងវិធីសាស្រ្តកំណត់ថ្លៃទឹក

ចំនួន ០២វគ្គសម្រាប់អង្គភាពរដ្ឋាករទឹក និងនៅដើមខែសីហា ឆ្នាំ២០១៥ កម្មវិធីWSP នឹងរៀបចំបញ្ចប់ និងដាក់ឱ្យប្រើប្រាស់សេចក្តីព្រាងប្រកាសស្តីពីការពិនិត្យ ឡើងវិញ និងការគំនត់ថ្លៃទឹក និងរៀបចំសិក្ខាសាលា ដើម្បីធ្វើការផ្សព្វផ្សាយឱ្យប្រើប្រាស់ជាផ្លូវការ ។



មានប្រសាសន៍នាឱកាសនោះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានថ្លែងអំណរគុណចំពោះធនាគារពិភពលោក ដែលបានផ្តល់ជំនួយបច្ចេកទេស ក្នុងការអនុវត្តគម្រោងចំនួន២ គឺ :គម្រោងបង្កើតប្រព័ន្ធព័ត៌មានគ្រប់គ្រងប្រតិបត្តិករទឹកស្អាតទូទាំងប្រទេសនិងសេចក្តីព្រាងបញ្ញត្តិសេដ្ឋកិច្ច និងវិធីសាស្ត្រកំណត់ថ្លៃទឹក ដែលការអនុវត្តគម្រោងទាំងពីរនេះទទួលលទ្ធផលគួរជាទី មោទនៈ ។ ឯកឧត្តម ទេសរដ្ឋមន្ត្រីបានលើកឡើងពីការខិតខំរបស់រាជរដ្ឋាភិបាលកម្ពុជា និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដើម្បីធ្វើយ៉ាងសម្រេចឱ្យបានតាមគោលដៅអភិវឌ្ឍន៍សហវត្សន៍ (MDG) ស្តីពីវិស័យទឹកស្អាតនៅកម្ពុជាគឺឱ្យវិស័យទឹកស្អាតបានទៅដល់ការប្រើប្រាស់របស់ប្រជាពលរដ្ឋក្នុងវិសាលភាពធំធេងប្រកបដោយគុណភាព និងតម្លៃសមរម្យ ដើម្បីរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានបញ្ជាក់ថាបន្ទាប់ពីគម្រោងនេះបានបញ្ចប់ទៅ នៅចុងឆ្នាំ២០១៥ នឹងបង្កលក្ខណៈងាយស្រួល ក្នុងការគ្រប់គ្រងតាមដាន ពីស្ថានភាពផ្គត់ទឹកស្អាត និងអាជីវកម្មទូទាំងប្រទេស ដែលតាមគម្រោងនេះយើងអាចដឹងបានដូចជា :ផែនទីទីតាំងភូមិសាស្ត្រ តំបន់សេវាកម្ម ប្រភពទឹក គុណភាពទឹក សមត្ថភាពផលិតកម្ម និងទុនវិនិយោគ ។ល។ ចំពោះគម្រោងស្តីពីវិធីសាស្ត្រកំណត់ថ្លៃទឹក គឺមានអត្ថប្រយោជន៍ឱ្យការកំណត់ថ្លៃទឹកមានលក្ខណៈសមរម្យ កុំឱ្យមានភាពខុសគ្នាខ្លាំងពេករវាងតំបន់មួយទៅតំបន់មួយ រឺពីខេត្តមួយ ទៅខេត្តមួយ គឺធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋមានលទ្ធផលជាវទឹកស្អាតប្រើប្រាស់សម្រាប់ទាំងអស់គ្នា ។

ជាចុងក្រោយភាគីពិភាក្សាទាំងពីរ បានសម្រេចថា បន្ទាប់ពីការធ្វើបញ្ចប់សេចក្តីព្រាងប្រកាស ស្តីពីការពិនិត្យឡើងវិញ នៃការកំណត់ថ្លៃទឹកលក់ នឹងរៀបចំធ្វើសិក្ខាសលា នៅក្នុងខែសីហា ឆ្នាំ២០១៥ ខាងមុខ ដើម្បីអញ្ជើញអាជីវករទឹកស្អាត ដៃគូពាក់ព័ន្ធ និងវិស័យឯកជនចូលរួម សែវយល់ពីការដាក់ឱ្យប្រើប្រាស់នូវសេចក្តីព្រាងប្រកាសខាងលើនេះ ។